ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ថវិកាសង្ខេប ឆ្នាំ ២០១៩

## BUDGET IN BRIEF Fiscal Year 2019

នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា

# មាតិកា


| | ទំព័រ |
|---|---|
| ជំពូក ១ បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០១៩ | ២ |
| ១.១. បញ្ហាប្រឈម និង ហានិភ័យ | ៣ |
| ១.២. គោលការណ៍នៃការរៀបចំថវិកាឆ្នាំ ២០១៩ | ៣ |
| ជំពូក ២ ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០១៩ | ៤ |
| ២.១. សូចនាករសេដ្ឋកិច្ច | ៤ |
| ២.២. កំណើនតាមវិស័យសំខាន់ៗ | ៦ |
| ជំពូក ៣ ក្របខណ្ឌថវិកាឆ្នាំ ២០១៩ | ៩ |
| ៣.១. ស្ថានភាពចំណូលថវិការដ្ឋ | ១០ |
| ៣.២. ស្ថានភាពចំណាយថវិការដ្ឋ | ១២ |
| ៣.៣. ថវិកាកម្មវិធីនៃក្រសួង ស្ថាប័ន | ១៩ |
| ៣.៤. ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០១៩ | ៣៧ |
| ៣.៥. គម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ | ៣៨ |
| ៣.៦. ស្ថានភាពបំណុល | ៣៩ |
| ជំពូក ៤ បទប្បញ្ញត្តិស្ដីពីពន្ធដារ | ៤០ |
| ជំពូក ៥ សេចក្ដីសន្និដ្ឋាន | ៤១ |
| ជំពូក ៦ តារាងឧបសម្ព័ន្ធ | ៤៣ |
| ៦.១. ចំណាយថវិកាចរន្តរបស់ក្រសួង ស្ថាប័ន តាមកម្មវិធី អនុកម្មវិធី | ៤៣ |
| ៦.២. ចំណាយថវិកាសរុបរបស់ក្រសួង ស្ថាប័ន | ៧៧ |

**ជំពូក ១  <u>បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០១៩</u>**

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដែលបានប្រសូតចេញពីការបោះឆ្នោតដោយសេរី យុត្តិធម៌ ត្រឹមត្រូវ និង មានតម្លាភាព ស្របទៅតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស បាន និងកំពុងបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ខ្លួន បន្តពីរាជរដ្ឋាភិបាលនីតិកាលទី៥ ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំឥតរាថយ និង កាន់តែស្វាហាប់ជាងពេលណាៗទាំងអស់ ក្នុងការបម្រើប្រជាជនទ្វេដង ក៏ដូចជាក្នុងការពន្លឿនកិច្ចអភិវឌ្ឍ និងជំរុញអនុវត្តការកែទម្រង់កាន់តែស៊ីជម្រៅ និងទូលំទូលាយលើគ្រប់វិស័យ ឆ្ពោះទៅរកអនាគតមួយដ៏រុងរឿង ស្របតាមឆន្ទៈ និងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជន។ ម៉្យាងទៀត និន្នាការនៃការផ្លាស់ប្តូរថ្មីនៅក្នុងបរិការណ៍ពិភពលោក ទាំងក្នុងទិដ្ឋភាពភូមិសាស្ត្រនយោបាយ ទាំងក្នុងទិដ្ឋភាពភូមិសាស្ត្រ សេដ្ឋកិច្ច និង ទាំងក្នុងទិដ្ឋភាពចរន្តនយោបាយ-សង្គម រួមទាំងបញ្ហាសន្តិសុខ នៅក្នុងតំបន់ និង ពិភពលោក អាចនឹងបង្កើនកម្រិតហានិភ័យដល់សេដ្ឋកិច្ចពិភពលោក ឱ្យកាន់តែខ្ពស់ថែមទៀត ទោះបីស្ថានភាពសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្នកំពុងមានលក្ខណៈប្រសើរជាងបណ្តាឆ្នាំកន្លងទៅក្តី។ ហេតុនេះ កម្ពុជាត្រូវខិតខំទ្វេដងថែមទៀត ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយ ហើយត្រូវមានភាពហ្មត់ចត់ និងភាពប្រុងប្រយ័ត្ននៅក្នុងការគ្រប់គ្រងហានិភ័យផ្សេងៗជាប់ជាប្រចាំ។



## ១.១. បញ្ហាប្រឈម និង ហានិភ័យ

និយាយជារួម កម្ពុជានៅតែអាចបន្តសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ នៅក្នុងរយៈពេលខ្លី និងមធ្យមខាងមុខនេះ ខណៈដែលបញ្ហាប្រឈម និងហានិភ័យកាន់តែកើនឡើងទាំងខាងក្នុង ទាំងខាងក្រៅ ដែលអាចនឹងប៉ះពាល់ដល់ចីរភាពនៃកំណើននេះ និងបង្កភាពរអាក់រអួលដល់កិច្ចអភិវឌ្ឍន៍ ដូចជា÷



**កត្តាខាងក្នុង**

- សម្ពាធនៃការកើនឡើងនៃតម្រូវការចំណាយថវិការដ្ឋ ជាពិសេសចំណាយបន្ទុកបុគ្គលិក ក្នុងខណៈដែលកំណើនចំណូលថវិកាបានឈានទៅកៀកនឹងពិតាននៃសក្តានុពល
- បញ្ហាប្រឈមចម្បងមួយចំនួន÷ ថ្លៃអគ្គិសនីនៅខ្ពស់, ប្រព័ន្ធដឹកជញ្ជូន និង ឡូជីស្ទីកនៅទន់ខ្សោយ, និន្នាការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមា ព្រមជាមួយ បែបបទនីតិវិធីខ្លះនៅស្មុគស្មាញ

**កត្តាខាងក្រៅ**

- ភាពមិនប្រាកដប្រជានៃប្រព័ន្ធអនុគ្រោះពន្ធលើពាណិជ្ជកម្មអន្តរជាតិពីសំណាក់ដៃគូខ្លះ
- សង្គ្រាមពាណិជ្ជកម្មពិភពលោក
- និន្នាការកំណើនជាបន្តបន្ទាប់នៃថ្លៃប្រេងលើទីផ្សារអន្តរជាតិ
- បញ្ហានយោបាយ និង សន្តិសុខជាសកល
- ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់បណ្តាប្រទេសអភិវឌ្ឍន៍នានា

## ១.២. គោលការណ៍នៃការរៀបចំថវិកាឆ្នាំ ២០១៩

ថវិកាឆ្នាំ ២០១៩ ត្រូវបានរៀបចំឡើងដោយផ្អែកលើ **គោលការណ៍គ្រឹះជាយុទ្ធសាស្ត្រ** សំខាន់ចំនួន ៤ ដែលក្នុងនោះរួមមាន÷

**គោលការណ៍គ្រឹះជាយុទ្ធសាស្ត្រ**

- ធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧,០%
- ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
- បន្តអនុវត្តកម្មវិធីអាទិភាព និងកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល
- ផ្តល់ការលើកទឹកចិត្តដល់ក្រសួង ស្ថាប័នណាដែលបុរេសកម្ម និង មានសមិទ្ធកម្ម ឬ លទ្ធផលការងារល្អ

ថវិកាឆ្នាំ ២០១៩ ត្រូវបានរៀបចំឡើងដោយបន្តប្រកាន់យក**គោលការណ៍ជាបច្ចេកទេស**សំខាន់ៗ ដូចខាងក្រោម÷




## ជំពូក ២ ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០១៩

### ២.១. សូចនាករសេដ្ឋកិច្ច

តាមការព្យាករណ៍ **កំណើនសេដ្ឋកិច្ច**កម្ពុជាបន្តសម្រេចបានក្នុងអត្រា ៧,១% ដែលប្រហាក់ប្រហែលនឹងកំណើនឆ្នាំ ២០១៨។ នៅក្នុងឆ្នាំ ២០១៩, **ផសស** ថ្លៃបច្ចុប្បន្នកើនឡើងដល់ ១០៩ ៨៩៤ ៩៤៩ លានរៀល សមមូលនឹងប្រមាណ ២៧ ២២២ លានដុល្លារអាមេរិក ខណៈ **ផសស សម្រាប់មនុស្សម្នាក់**ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១ ៧០៦ ដុល្លារអាមេរិក ធៀបនឹង ១ ៥៦៣ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៨។ ចំណែក**អត្រាប្តូរប្រាក់រៀល** គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់ ៤ ០៥០ រៀល ក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៩។ **ឱនភាពគណនីចរន្ត**(រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៧,១% នៃ ផសស ក្នុងឆ្នាំ ២០១៩។ ភាពល្អប្រសើរឡើងនៃគណនីចរន្តនេះ នឹងឆ្លុះបញ្ចាំងតាមរយៈការរំពឹងទុកនៃភាពរួមតូចនៃឱនភាពសមតុល្យពាណិជ្ជកម្ម, ការកើនឡើងខ្ពស់នៃចំណូលពីភ្ញៀវទេសចរអន្តរជាតិ និងកំណើននៃប្រាក់បង្វែរ

ឯកជនពីបរទេស (Remittances)។ **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ប្រមាណ ១១ ០៥៩ លានដុល្លារ អាមេរិក ដែលធានាការនាំចូលបាន ៦,៥ ខែ នៅឆ្នាំ ២០១៩។

| **សូចនាករសេដ្ឋកិច្ច** | **២០១៧** | **២០១៨** | **២០១៩** |
|---|---|---|---|
| | **អនុវត្ត** | **ប៉ាន់ស្មាន** | **ព្យាករណ៍** |
| ផសស តាមថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ៨៩ ៦៤៧ | ៩៩ ៣៣២ | ១០៩ ៨៩៥ |
| កំណើនពិតនៃ ផសស (%) | ៧,០% | ៧,០% | ៧,១% |
| ផសស សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ១ ៤២៧ | ១ ៥៦៣ | ១ ៧០៦ |
| អតិផរណា (ជាមធ្យមប្រចាំឆ្នាំ) | ២,៩% | ៣,៤% | ៣,១% |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/ រៀល) | ៤ ០៤៥ | ៤ ០៣៧ | ៤ ០៣៧ |
| សមតុល្យគណនីចរន្ត (% នៃ ផសស) | -៦,៩% | -៧,៣% | -៧,១% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ៨ ៧៥៨ | ៩ ៤៩៤ | ១១ ០៥៩ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៦,៤ | ៦,២ | ៦,៥ |




*ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិនៃកម្ពុជា (២០១០-២០១៦), ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៧-២០១៩)*

- អត្រាអតិផរណាមធ្យមប្រចាំឆ្នាំត្រូវបានប៉ាន់ស្មានថា នឹងមានការកើនឡើងបន្តិចក្នុងអត្រា ៣,៤% ក្នុងឆ្នាំ ២០១៨ ហើយនឹងថយចុះមកត្រឹម ៣,១% ក្នុងឆ្នាំ ២០១៩ ស្របនឹងការរំពឹងទុកនៃកំណើនយឺតនៃថ្លៃប្រេងលើទីផ្សារអន្តរជាតិ និងកំណើនយឺតជាងមុននៃថ្លៃម្ហូបអាហារ ដោយសារការអនុវត្តវិធានការមួយចំនួនដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ដូចជា÷ ការបញ្ចុះអត្រាពន្ធនាំចូលចំពោះម្ហូបអាហារ, ការលុបភាស៊ីអាជីវកម្មសត្តឃាតដ្ឋាន, ការបង្កើនភាពប្រកួតប្រជែងក្នុងអាជីវកម្មសត្តឃាតដ្ឋាន និងការបង្កើនផលិតកម្មបន្លែក្នុងស្រុក តាមរយៈការអនុវត្តគម្រោងរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍។
- អត្រាប្តូរប្រាក់រៀលជាមធ្យមប្រចាំឆ្នាំគឺ **៤ ០៣៧** រៀលក្នុងមួយដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០១៨ និងឆ្នាំ ២០១៩ ដែលជាអត្រាមួយអាចរក្សាស្ថិរភាពអតិផរណា និង ស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ចជារួម។

## ២.២. កំណើនតាមវិស័យសំខាន់ៗ

តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ ២០១៩ ត្រូវបានទ្រទ្រង់ដោយ÷

**(ទី១)**-កំណើននៃវិស័យឧស្សាហកម្មនៅបន្តរក្សាភាពរឹងមាំ ក្នុងអត្រាកំណើនប្រចាំឆ្នាំក្នុងរង្វង់ ១០,០% ដែលគាំទ្រដោយភាពរឹងមាំនៃវិស័យសំណង់ ការបន្តកំណើននៃវិស័យកាត់ដេរ

ស្របគ្នានឹងសន្ទុះកំណើនខ្ពស់នៃវិស័យកម្មន្តសាលមិនមែនកាត់ដេរ ទាំងសម្រាប់នាំចេញ និងបម្រើទីផ្សារក្នុងស្រុក។ អនុវិស័យសំណង់គាំទ្រដោយសន្ទុះកំណើននៃសំណង់ថ្លៃមធ្យម និងសមរម្យតាមរយៈការអនុវត្តគម្រោងអភិវឌ្ឍន៍លំនៅដ្ឋានតម្លៃសមរម្យ និងភាពជឿជាក់ចំពោះការវិនិយោគនៅកម្ពុជាដែលជួយប៉ះប៉ូវការធ្លាក់ចុះនៃសំណង់ថ្លៃខ្ពស់មួយផ្នែក។ វិស័យកាត់ដេរនៅបន្តកំណើនប្រហាក់ប្រហែលនឹងឆ្នាំមុន ដោយសារភាពល្អប្រសើរនៃស្ថានភាពសេដ្ឋកិច្ចពិភពលោកជាពិសេសសេដ្ឋកិច្ចនៃបណ្តាប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជា។ ទន្ទឹមនេះ អនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរ ដូចជាម្ហូបអាហារនិងភេសជ្ជៈ ឧស្សាហកម្មដំឡើងយានយន្ត គ្រឿងបង្គុំអេឡិចត្រូនិកគ្រឿងបន្លាស់ គ្រឿងសង្ហារឹម កង់ និងស៊ីម៉ង់ត៍ជាដើម ទាំងសម្រាប់បម្រើឱ្យការនាំចេញ និងតម្រូវការទីផ្សារក្នុងស្រុក នឹងមានសន្ទុះកំណើនខ្ពស់ ទាំងការពង្រីកការវិនិយោគដែលមានស្រាប់និងការវិនិយោគថ្មី។

**(ទី២)**-វិស័យសេវាកម្មនៅបន្តកំណើនប្រមាណ ៧,០% ដែលគាំទ្រដោយកំណើននៃអនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនខ្ពស់នៃចំនួនភ្ញៀវទេសចរអន្តរជាតិ ជាពិសេសមកពីតំបន់អាស៊ី ដោយសារការលើកទឹកចិត្តឱ្យមានការបើកជើង-ហោះហើរត្រង់កាន់តែច្រើន និងការដាក់ចេញនូវគោលនយោបាយនានាក្នុងការទាក់ទាញភ្ញៀវទេសចរបន្ថែម។ អនុវិស័យលក់ដុំ-រាយក៏នៅរក្សាកំណើនល្អប្រសើរ ដែលគាំទ្រដោយកំណើននៃការប្រើប្រាស់ក្នុងស្រុក ដោយសារកំណើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។ ទន្ទឹមនេះ អនុវិស័យអចលនទ្រព្យក៏ត្រូវបានរំពឹងថានឹងបន្តកំណើនខ្ពស់ស្របតាមនិន្នាការនៃអនុវិស័យសំណង់ផងដែរ។ ដោយឡែក អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ត្រូវបានរំពឹងថានឹងបន្តរក្សាកំណើនប្រហាក់-ប្រហែលនឹងឆ្នាំ ២០១៨ ដែលជំរុញដោយការអនុវត្តគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ដូចជា÷ ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ការបើកឱ្យដំណើរការឡើងវិញខ្សែផ្លូវរថភ្លើងទិសខាងជើងពីភ្នំពេញទៅប៉ោយប៉ែត ការពង្រីកព្រលានយន្តហោះ និងកំពង់ផែ ព្រមទាំងផែនការវិនិយោគថ្មីៗលើបច្ចេកវិទ្យាជំនាន់ថ្មី (5G) លើការពង្រីកវិសាលភាពអ៊ិនធឺណិតឱ្យគ្របដណ្តប់ដល់តំបន់ដាច់ស្រយាល។

**(ទី៣)**-វិស័យកសិកម្មអាចសម្រេចបានកំណើនក្នុងរង្វង់ ១,៨% ដែលទ្រទ្រង់ដោយអនុវិស័យដំណាំនិងជលផល។ អនុវិស័យដំណាំត្រូវបានរំពឹងថានឹងមានកំណើនប្រហាក់ប្រហែលឆ្នាំមុន ដោយសារភាពអំណោយផលនៃកត្តាអាកាសធាតុ ភាពប្រសើរឡើងនៃប្រព័ន្ធធារាសាស្ត្រ និងការកើនឡើងនៃថ្លៃអង្ករនៅលើទីផ្សារអន្តរជាតិ ព្រមទាំងការកើនឡើងនៃដំណាំបម្រើឱ្យការនាំចេញផ្សេងទៀត ដូចជាកៅស៊ូ និងចេកជាដើម។ អនុវិស័យនេសាទត្រូវបានរំពឹងថានឹងមានកំណើនល្អប្រសើរផងដែរ ដែលត្រូវបានជំរុញដោយការបន្តកំណើនខ្ពស់នៃអនុវិស័យវារីវប្បកម្មស្របតាមនិន្នាការកើនឡើងនៃការវិនិយោគពីសំណាក់វិស័យឯកជន និងការចូលរួមពីដៃគូអភិវឌ្ឍន៍។ អនុវិស័យចិញ្ចឹមសត្វក៏ត្រូវបានព្យាករថានឹងមានកំណើនល្អ ដោយសារការបន្តកំណើននៃការចិញ្ចឹមគោ និងការចិញ្ចឹមមាន់តាមបែបធម្មជាតិក្នុងគោលដៅពាណិជ្ជកម្ម ព្រមទាំងកំណើនផលិតកម្មជ្រូកដោយសារតែការងើបឡើងវិញនៃថ្លៃជ្រូករស់។



**ជំពូក ៣ <u>ក្របខណ្ឌថវិកាឆ្នាំ ២០១៩</u>**

ឈរលើគោលការណ៍ខាងលើ ក៏ដូចជាក្នុងក្របខណ្ឌនៃកំណើនសេដ្ឋកិច្ច ដែលត្រូវបានគ្រោងក្នុងរង្វង់ ៧% ព្រមជាមួយនឹងសេណារីយ៉ូចំណូលដែលមានលក្ខណៈសុទិដ្ឋិនិយម និង ដោយឈរលើមូលដ្ឋាននៃលទ្ធផលល្អប្រសើរនៃការអនុវត្តចំណូល ពិសេសចំណូលគយ និង ចំណូលពន្ធដារឆ្នាំ ២០១៧ និង ឆ្នាំ ២០១៨ <u>ក្របខណ្ឌថវិកាឆ្នាំ ២០១៩ ត្រូវបានរៀបចំឡើងដោយធ្វើការកំណត់ដូចតទៅ÷</u>

| សូចនាករថវិកា | ២០១៧ | | ២០១៨ | ២០១៩ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | ច្បាប់ |
| **ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ (%ផសស)** | ១៨,៥១ | ២០,២៤ | ១៨,៧១ | ១៩,២៨ |
| ***ចំណូលចរន្ត (%ផសស)*** | ១៨,៣៥ | ២០,០៨ | ១៨,៥៣ | ១៩,១០ |
| **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ (%ផសស)** | ២៣,៥៧ | ២៣,៤៥ | ២៤,៥៤ | ២៤,៧២ |
| ***ចំណាយចរន្ត (%ផសស)*** | ១៥,៣៧ | ១៥,៦៦ | ១៦,០៥ | ១៦,៣០ |
| **អតិរេកចរន្ត (%ផសស)** | ២,៩៧ | ៤,៤៣ | ២,៤៨ | ២,៨១ |
| **ឱនភាពសរុប (%ផសស)** | -៥,០៥ | -៣,២១ | -៥,៨៣ | -៥,៤៤ |

- **<u>ចំណូលក្នុងប្រទេសថវិការដ្ឋ</u>** ត្រូវបានគ្រោង ១៩,២៨% នៃ ផសស ស្មើនឹងចំនួន ២១ ១៨៦ ២២៨ លានរៀល។
- **<u>ចំណាយសរុបថវិការដ្ឋ</u>** ត្រូវបានគ្រោង ២៤,៧២% នៃ ផសស ស្មើនឹងចំនួន ២៧ ១៦៤ ៩៩៦ លានរៀល។
- **<u>អតិរេកថវិកាចរន្ត</u>** អាចរក្សាបានក្នុងកម្រិតប្រមាណ ២,៨១% នៃ ផសស។
- **<u>ឱនភាពថវិកាសរុប</u>** ស្មើនឹង -៥,៤៤% នៃ ផសស ស្របតាមគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (Fiscal Consolidation)។

ឯកតា លានរៀល




### ៣.១. ស្ថានភាពចំណូលថវិការដ្ឋ

ក្នុងក្របខណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលសរុបថវិការដ្ឋ ឬចំណូលសរុបថវិកាជាតិ ឱ្យស្មើនឹង ២៦ ៧៥៩ ៩៩៦ លានរៀល ក្នុងនោះ ចំណូលចរន្តថ្នាក់ជាតិឱ្យស្មើនឹង ១៩ ៥៩៣ ១១១ លានរៀល (ដែលរួមមាន ចំណូលសារពើពន្ធ ១៦ ៨៧៩ ០០០ លានរៀល និង ចំណូលមិនមែនសារពើពន្ធ ២ ៧១៤ ១១១ លានរៀល)។ ដោយឡែក សម្រាប់ចំណូល

មូលធនថវិការដ្ឋ ត្រូវបានគ្រោងចំនួន ៥ ៧៦៦ ៩១៧ លានរៀល, ត្រូវជា ៥,២៥% នៃ ផសស គឺមានកំណើន ១៥,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ក្នុងនោះចំណូលមូលធនដោយហិរញ្ញប្បទានពីក្រៅប្រទេស ស្មើនឹងប្រមាណ ២០% នៃចំណាយថវិការដ្ឋសរុបឆ្នាំ ២០១៩ ប៉ុណ្ណោះ។






**ចំណូលមូលធន** ត្រូវសម្រេចឱ្យបានចំនួន ៥ ៧៦៦ ៩១៧ លានរៀល ក្នុងនោះ

- ចំណូលមូលធនក្នុងប្រទេស ១៩៣ ១៤៩ លានរៀល
- ចំណូលមូលធនក្រៅប្រទេស ៥ ៥៧៣ ៧៦៨ លានរៀល




## ៣.២. ស្ថានភាពចំណាយថវិការដ្ឋ

សម្រាប់ឆ្នាំ ២០១៩ **ចំណាយសរុបថវិការដ្ឋ** ឬ **ចំណាយសរុបថវិកាជាតិ** ត្រូវបានគ្រោងចំនួន ២៧ ១៦៤ ៩៩៦ លានរៀល ត្រូវជា ២៤,៧២% នៃ ផសស គឺមានកំណើន ១១,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ដែលក្នុងនោះ (១)-**ចំណាយចរន្តថវិការដ្ឋ**មានចំនួន ១៧ ៩០៧ ៥៤៩ លានរៀល ត្រូវជា ១៦,៣០% នៃ ផសស គឺមានកំណើន ១២,៣% ធៀបនឹងច្បាប់ឆ្នាំ ២០១៨

និង (២)-**ចំណាយមូលធនថវិការដ្ឋ**មានចំនួន ៩ ២៥៧ ៤៤៧ លានរៀល ត្រូវជា ៨,៤២% នៃផសស គឺមានកំណើន ៩,៨% ធៀបនឹងច្បាប់ឆ្នាំ ២០១៨។




## ចំណាយចរន្ត



**បន្ទុកបុគ្គលិកសរុប ÷ ៨ ៣៣៥ ១០២ លានរៀល**

- ថ្នាក់ជាតិ ÷ ៧ ៨៦២ ៥៣៧ លានរៀល
- ថ្នាក់ក្រោមជាតិ ÷ ៤៧២ ៥៦៥ លានរៀល



**ក្រៅបន្ទុកបុគ្គលិកសរុប ÷ ៩ ៥៧២ ៤៤៧ លានរៀល**

- ថ្នាក់ជាតិ ÷ ៨ ៩៦៤ ៧៤៣ លានរៀល



- ថ្នាក់ក្រោមជាតិ ÷ ១ ៤០៧ ៣៧២ លានរៀល*

*សំគាល់÷ *ទំហំចំណាយចរន្តក្រៅបន្ទុកបុគ្គលិកថ្នាក់ក្រោមជាតិបានប្លូកបញ្ចូលនូវឥណទានឧបត្ថម្ភកធនពីថ្នាក់ជាតិចំនួន ៧៩៩ ៦៦៨ លានរៀល។*

## ចំណាយមូលធន

**វិនិយោគសាធារណៈហិរញ្ញប្បទានក្នុងប្រទេស**



**សរុប÷** ៣ ០២៧ ៧៣១ លានរៀល

- ថ្នាក់ជាតិ ÷ ២ ៧០៨ ០៣២ លានរៀល
- ថ្នាក់ក្រោមជាតិ ÷ ៣១៩ ៦៩៩ លានរៀល



**វិនិយោគសាធារណៈហិរញ្ញប្បទានក្រៅប្រទេស**

៥ ៣២៣ ៧៦៨ លានរៀល

**ការទូទាត់ប្រាក់ខ្ចី** ៩០៥ ៩៤៨ លានរៀល



### ក. ចំណាយចរន្តថ្នាក់ជាតិ




### ក.១. ចំណាយលើបន្ទុកបុគ្គលិក

ចំណាយលើបន្ទុកបុគ្គលិក ត្រូវបានគ្រោងចំនួន ៧ ៨៦២ ៥៣៧ លានរៀល សម្រាប់ (១)-ការដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា ១០,០% តាមតម្លៃឯកតាសន្ទស្សន៍ ២ ៣៤០ រៀល ដោយអនុវត្ត ចាប់ពីខែមករា ឆ្នាំ ២០១៩, (២)-ការដំឡើងប្រាក់បំណាច់មុខងារនឹងត្រូវអនុវត្ត ចាប់ពីខែមេសា ឆ្នាំ ២០១៩ ដោយផ្តល់បន្ថែម ៣០ ០០០ រៀល ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី ៧៥០ ០០០ រៀល ចុះក្រោម, (៣)-ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យាពី ៦០០ ០០០ រៀល ទៅដល់ ៦៥០ ០០០ រៀល ដោយអនុវត្តចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ ២០១៩។ ចំពោះការបើកប្រាក់បៀវត្សនឹងត្រូវធ្វើឡើងចំនួន ២ ដងក្នុងមួយខែ តាមប្រព័ន្ធធនាគារចាប់ពីខែមករា ឆ្នាំ ២០១៩ ផងដែរ។

ក្រៅពីបានដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន **៥០ ប៊ីលានរៀល** ជាមូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជននៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល។ ទន្ទឹមគ្នានេះ បន្ថែមពីលើប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គមចំនួនពីរ គឺប្រាក់ឧបត្ថម្ភ

មាតុភាពដល់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រី និងប្រាក់ឧបត្ថម្ភបុណ្យ-សពមន្ត្រីរាជការដែលទទួលមរណភាពក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារ ដើម្បីរៀបចំពិធីបុណ្យសពតាមប្រពៃណីដែលត្រូវបានដាក់ឱ្យអនុវត្តនៅដើមឆ្នាំ ២០១៨, រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន **៦ ប៊ីលានរៀល** ដើម្បីទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ នៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល។ ជាមួយគ្នានេះ ក៏មានថវិកា **២០ ប៊ីលានរៀល** សម្រាប់ផ្តល់លទ្ធភាពដល់ក្រសួង ស្ថាប័នអាចជ្រើសរើសមន្ត្រីមានសមត្ថភាពនិងជំនាញខ្ពស់ចូលបម្រើការងាររដ្ឋផងដែរ។ ចំពោះ**ប្រាក់សោធននិវត្ត** ក៏ត្រូវបានគ្រោងថវិកាចំនួន **៦០ ប៊ីលានរៀល** សម្រាប់ការដំឡើងរបបសោធនប្រចាំខែទាបបំផុត និងការ-កាត់បន្ថយគម្លាតរបបសោធនរបស់និវត្តជន រវាងអ្នកទទួលបានសោធនទាប និងអ្នកទទួលបានសោធនខ្ពស់ និងរវាងនិវត្តជនថ្មី និងនិវត្តជនចាស់ ជូនដល់និវត្តជនដែលជាអតីតមន្ត្រីរាជការ-ស៊ីវិល និងកងកម្លាំងប្រដាប់អាវុធផងដែរ។

**ក.២. ចំណាយមិនមែនបន្ទុកបុគ្គលិក**

ត្រូវបានគ្រោងចំនួន ៨ ៩៦៤ ៧៤៣ លានរៀល, មានសមាមាត្រ ស្មើនឹង ៥៣,២៨% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៨,១៦% នៃ ផសស គឺមានកំណើន ២២,៨% ធៀបនឹងច្បាប់ឆ្នាំ ២០១៨, ហើយត្រូវបានវិភាជដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់តាមវិស័យនីមួយៗ ដូចខាងក្រោម÷

**<u>វិស័យរដ្ឋបាលទូទៅ</u>**

- លើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលចំណូលសារពើពន្ធ
- គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- គាំទ្រកំណែទម្រង់វិស័យដីធ្លី
- គាំទ្រ និងពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម
- គាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ
- បង្កើនប្រសិទ្ធភាពនៃកិច្ចការទូត តាមរយៈបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុដល់មន្ត្រីការទូត។

**<u>វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់</u>**

- គាំទ្រដល់ការពង្រឹងសមត្ថភាពរបស់នគរបាល និងកងកម្លាំងប្រដាប់អាវុធ
- បន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ

- បង្កើនការគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ
- គាំទ្រកិច្ចដំណើរការរដ្ឋបាល និងអន្តរាគមន៍ផ្សេងៗ
- គាំទ្រការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព
- គាំទ្រដល់ប្រតិបត្តិការផលិតអត្តសញ្ញាណប័ណ្ណ
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តគាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីកម្ពុជា។

**<u>វិស័យសង្គមកិច្ច</u>**

- ពង្រឹងគុណភាព និងគាំទ្រសេវាអប់រំ
- អភិវឌ្ឍជំនាញ និងវិស័យការងារ
- លើកកម្ពស់គុណភាពសេវាសុខាភិបាល
- ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ
- ឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន
- បង្កើនការឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី ខេត្ត និងការឧបត្ថម្ភ គាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា ដើម្បីផ្តល់សេវាជូនជនពិការ
- ផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រនៅតាមសហគមន៍ក្នុងជំហានសាកល្បង
- ការពារ និងអភិរក្សធនធានធម្មជាតិ
- អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ
- សុខដុមនីយកម្មសាសនា។

**<u>វិស័យសេដ្ឋកិច្ច</u>**

- បន្តការលើកកម្ពស់បច្ចេកទេសកសិកម្ម
- ជំរុញផលិតកម្មស្បៀង ពិសេសការចិញ្ចឹមសត្វ និងមច្ឆាវប្បកម្ម
- ពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល

- បង្កើនការគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ
- ជំរុញការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ
- ជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ
- ជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍
- បន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា
- បណ្តុះបណ្តាលធនធានមនុស្ស
- បន្តជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត
- ត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ
- អភិវឌ្ឍប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិក
- ពង្រឹងនូវក្របខណ្ឌ និងយន្តការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម
- អភិវឌ្ឍប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ។

**ព័ត៌មានបន្ថែមសម្រាប់ទំហំចំណាយថវិកាសរុប (ចំណាយចរន្ត និងចំណាយមូលធន ក្នុងប្រទេស និងក្រៅប្រទេស) របស់ក្រសួង ស្ថាប័ន មានក្នុងតារាងឧបសម្ព័ន្ធទី ៣៩**

លើសពីនេះ សម្រាប់ឆ្នាំ ២០១៩ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាឆ្លើយតបនឹងសកម្មភាពគាំពារសង្គមដែលរួមមានជាអាទិ៍ ដូចជា÷

- **បន្តគាំទ្រការថែទាំសុខភាពសម្រាប់កម្មករ÷** បានត្រៀមថវិកាក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្តល់លទ្ធភាពឱ្យកម្មករ (ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ) ដែលមិនទាន់ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ទទួលបានរបបថែទាំសុខភាពដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ។
- **បន្តការឧបត្ថម្ភមាតុភាពសម្រាប់កម្មករនិយោជិត÷** បានគ្រោងនៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់បន្តបើកផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មការិនីនៅក្រោយពេលសម្រាលកូន និងសម្រាកលំហែមាតុភាព។
- **ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា÷** បានគ្រោងថវិកានៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់បង្កើន “**មូលនិធិគន្ធបុប្ផាកម្ពុជា**”, បន្ថែមលើថវិកាដែល

ត្រូវផ្តល់ផ្ទាល់ទៅមន្ទីរពេទ្យគន្ធបុប្ផាសម្រាប់ចំណាយប្រតិបត្តិការឆ្នាំ ២០១៩, ដើម្បីធានានិរន្តរភាព គុណភាព និងប្រសិទ្ធភាព របស់មន្ទីរពេទ្យផង និងធានាការផ្តល់សេវាដោយមិនយកថ្លៃជូនដល់កុមារនៃគ្រួសារក្រីក្រផង។

- **ការបន្តសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការចុះសួរសុខទុក្ខកម្មករ-កម្មការិនី** តាមបណ្តារោងចក្រ សហគ្រាស ដើម្បីស្វែងយល់និងរកដំណោះស្រាយសមស្របជូនកម្មករ-កម្មការិនី ក៏ដូចជាជំរុញគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។
- **កម្មវិធីសង្គហទានសង្គមសម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារតូច÷** បានគ្រោងថវិកាសម្រាប់ឧបត្ថម្ភពេលពិនិត្យផ្ទៃពោះ ចំនួន ៤ លើក, ១ លើក ៤ ម៉ឺនរៀល, ពេលសម្រាលកូននៅមណ្ឌលសុខភាព ឬ ពេទ្យរដ្ឋ ជូន ២០ម៉ឺនរៀល, ឧបត្ថម្ភ ១០ លើកទៀត ១លើក ៤ ម៉ឺនរៀល ពេលទៅទទួលថ្នាំបង្ការ រហូតដល់កុមារអាយុ ២ ឆ្នាំ។

## ខ. ចំណាយមូលធនថ្នាក់ជាតិ

ត្រូវបានគ្រោងចំនួន ៨ ៩៣៧ ៧៤៨ លានរៀល មានសមាមាត្រ ស្មើនឹង ៣៤,៧% នៃចំណាយថវិកាថ្នាក់ជាតិសរុប ត្រូវជា ៨,១៣% នៃ ផសស គឺមានកំណើន ៨,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៨។ គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិថយចុះ -៧,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៨, ហើយត្រូវជា ២,៤៦% នៃ ផសស, ដែលការធ្លាក់ចុះនេះគឺដោយសារការអនុវត្តគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា។ ប៉ុន្តែគួរកត់សំគាល់ថា ការ-ថយចុះនេះតែលើចំណាយវិនិយោគដែលមិនគាំទ្រផ្ទាល់ដល់កំណើននិងភាពប្រកួតប្រជែងកម្ពុជាដូចជាការសាងសង់អគាររដ្ឋបាលជាដើម, ដោយឡែក ចំណាយលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលគាំទ្រដល់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងកម្ពុជាមិនថយចុះទេ ហើយចំណាយនេះមានគោលដៅផ្តល់ហិរញ្ញប្បទានដល់គម្រោង/កម្មវិធីក្នុងវិស័យអាទិភាព ដោយផ្តោតទៅលើការ-ទ្រទ្រង់កំណើនសេដ្ឋកិច្ច ការលើកកម្ពស់ភាពប្រកួតប្រជែង និងផលិតភាពសេដ្ឋកិច្ច ដូចជា÷

- ការកសាង និងជួសជុលផ្លូវថ្នល់ ជាពិសេសការស្តារនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលទទួលរងផលប៉ះពាល់ដោយសារទឹកជំនន់, និងកសាងកំពង់ផែទន្លេ
- ការបន្តស្តារនិងកសាងប្រព័ន្ធធារាសាស្ត្រ និងលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ ពិសេសលើកកម្ពស់ការគ្រប់គ្រង និងទប់ទល់នឹងទឹកជំនន់
- ការបន្តសាងសង់ និង ជួសជុលសាលារៀននៅតាមបណ្តាខេត្ត

- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ, វិស័យគមនាគមន៍ និង ដឹកជញ្ជូន និងវិស័យអាទិភាពផ្សេងៗទៀត ដូចជា សុខាភិបាល និងការផ្គត់ផ្គង់ទឹកស្អាត ជាដើម
- ការបន្តអនុវត្តសាកល្បងនូវកម្មវិធីសាច់ប្រាក់ពលកម្ម (Cash For Work) ដែលជាអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាលក្នុងការបង្កើតការងារនៅទីជនបទ
- ការបន្តវិនិយោគលើវិស័យអគ្គិសនី ដើម្បីបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះថ្លៃអគ្គិសនីនៅជនបទ
- ការផ្តល់ថវិកាគម្រោងវិនិយោគផ្ទាល់ក្នុងខេត្តត្បូងឃ្មុំ
- ការបន្តវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យកសិកម្ម និងការវិនិយោគលើការជំរុញ ផលិតកម្មស្បៀង ជាពិសេសការផលិតស្រូវ និងបន្លែ

### ៣.៣. ថវិកាកម្មវិធីនៃក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័នទាំង ៣៩ បានអនុវត្តថវិកាកម្មវិធីពេញលេញចាប់ពីឆ្នាំ ២០១៨។

**២០១៥**

១.ក្រ.អប់រំ,
២.ក្រ.សុខាភិបាល,
៣.ក្រ.ការងារ,
៤.ក្រ.កិច្ចការនារី,
៥.ក្រ.កសិកម្ម,
៦.ក្រ.អភិវឌ្ឍជនបទ,
៧.ក្រ.សាធារណការ,
៨.ក្រ.សេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
៩.ក្រ.ដែនដី,
១០.ក្រ.យុត្តិធម៌

**២០១៦**

១.ក្រ.ព័ត៌មាន,
២.ក្រ.បរិស្ថាន,
៣.ក្រ.សង្គមកិច្ច,
៤.អាកាសចរស៊ីវិល,
៥.ក្រ.ពាណិជ្ជកម្ម,
៦.ក្រ.ប្រៃសណីយ៍,
៧.ក្រ.ទេសចរណ៍,
៨.ក្រ.ធនធានទឹក,
៩.តុលាការកំពូល,
១០.សាលាឧទ្ធរណ៍
១១.អគ្គ.រដ្ឋសភា,
១២.អគ្គ.ព្រឹទ្ធសភា,
១៣.ក្រ.ការបរទេស,
១៤.អាជ្ញាធរសវនកម្មជាតិ,
១៥.អង្គភាពប្រឆាំងអំពើពុករលួយ,

**២០១៧**

១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
២.ក្រុមប្រឹក្សាធម្មនុញ្ញ,
៣.ក្រ.ព្រះបរមរាជវាំង,
៤.ក្រ.ទំនាក់ទំនងសភា,
៥. គណៈកម្មការជាតិរៀបចំការបោះឆ្នោត
៦.ក្រ.ធម្មការ,
៧.ក្រ.រ៉ែ និងថាមពល
៨.ក្រ.វប្បធម៌
៩.ក្រ.មុខងារ,
១០. ក្រ.ផែនការ,
១១. ក្រ.ឧស្សាហកម្ម,

**២០១៨**

១.ក្រ.មហាផ្ទៃ,
២.ក្រ.ការពារជាតិ,
៣.ទីស្តីការគណៈរដ្ឋមន្ត្រី,

**ក្រសួងអប់រំ យុវជន និងកីឡា** មានគោលនយោបាយចំនួន២ គឺ÷

ទី ១ ÷ ធានាឲ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា

ទី ២ ÷ ធានាភាពស័កសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១. ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ

២. ការអភិវឌ្ឍឧត្តមសិក្សានិងការស្រាវជ្រាវ

៣. ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

៤. ការអភិវឌ្ឍជំនាញបច្ចេកទេសនិងជំនាញទន់សម្រាប់យុវជន

៥. ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ

២ ៥៩៥ ៦០៨ លានរៀល

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១ នៃឧបសម្ព័ន្ធ</u>

**ក្រសួងសុខាភិបាល** មានគោលនយោបាយចំនួន ១ គឺ÷អភិវឌ្ឍន៍ប្រព័ន្ធសុខាភិបាល ដោយផ្តល់លទ្ធភាពទទួលបាននូវសេវាសុខភាពប្រកបដោយគុណភាព និងសមធម៌ ដើម្បីកែលម្អស្ថានភាពសុខភាព និងសុខុមាលភាពប្រជាពលរដ្ឋកម្ពុជាគ្រប់រូបផ្តោតលើ ស្ត្រី កុមារ ជនក្រីក្រ ជនងាយរងគ្រោះ និងចាស់ជរា។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ÷

១. សុខភាពបន្តពូជយុវវ័យ មាតា ទារក កុមារ និងអាហាររូបត្ថម្ភ

២. ប្រយុទ្ធជំងឺឆ្លង

៣. ប្រយុទ្ធជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត

៤. ពង្រឹងប្រព័ន្ធសុខាភិបាល

១ ៥៩៥ ៥២៥ លានរៀល

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២នៃឧបសម្ព័ន្ធ</u>

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**មានគោលនយោបាយ ចំនួន ១ គឺ÷ ពង្រឹងប្រព័ន្ធគាំពារ និងផ្តល់សេវាសុខុមាភាពសង្គម ប្រកបដោយប្រសិទ្ធភាព និងសមធម៌។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៣ គឺ÷

៩៣ ០៧១ លានរៀល

១. ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម

២. ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ

៣. ពង្រឹងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣នៃឧបសម្ព័ន្ធ</u>

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**: មានគោលនយោបាយ ចំនួន ១ គឺ÷ ការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

២៣៣ ៩៣៦ លានរៀល

១. ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

២. ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

៣. ការអភិវឌ្ឍមុខរបរ និងការងារ

៤. ការអភិវឌ្ឍរបបសន្តិសុខសង្គម

៥. ការពង្រឹងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៤នៃឧបសម្ព័ន្ធ</u>

**ក្រសួងបរិស្ថាន** មានគោលនយោបាយចំនួន ១ គឺ÷ កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និង ការគ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាព។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

**៨៥ ៧៨២ លានរៀល**

១. កិច្ចគាំពារបរិស្ថាន

២. ការគ្រប់គ្រងតំបន់ការពារធម្មជាតិ

៣. ការគ្រប់គ្រងការអភិវឌ្ឍដោយចីរភាព

៤. ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានបរិស្ថាន

៥. ការពង្រឹងអភិបាលកិច្ចល្អ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៥នៃឧបសម្ព័ន្ធ

**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** មានគោលនយោបាយចំនួន ១ គឺ÷ អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

**១៨០ ១៨៦ លានរៀល**

១. កិច្ចគាំពារបេតិកភណ្ឌវប្បធម៌រូបី

២. ការលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី

៣. ការពង្រឹងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៦នៃឧបសម្ព័ន្ធ

**ក្រសួងព័ត៌មាន**មានគោលនយោបាយចំនួន ១ គឺ៖ ការលើកម្ពស់សេវាផ្តល់ព័ត៌មាន និងធានាឱ្យបាននូវសិទ្ធិទទួលបានព័ត៌មានពេញលេញ ទាន់ពេលវេលា និងសុក្រឹត្យ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ៖

៨៥ ១៧៩ លានរៀល

ការគ្រប់គ្រង និងអភិវឌ្ឍវិស័យព័ត៌មាន

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៧នៃឧបសម្ព័ន្ធ

**ក្រសួងកិច្ចការនារី**មានគោលនយោបាយចំនួន ១ គឺ៖ ការលើកកម្ពស់ស្ថានភាព សេដ្ឋកិច្ច- សង្គម និងនយោបាយរបស់ស្ត្រីឱ្យក្លាយជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍប្រទេស និងសុភមង្គលគ្រួសារ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ៖

៥០ ៨៨៨ លានរៀល

១. កែប្រែស្ថានភាពសេដ្ឋកិច្ច- សង្គមរបស់ស្ត្រី
២. កិច្ចការពារផ្លូវច្បាប់ចំពោះស្ត្រី និងក្មេងស្រី
៣. ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយជាតិ និងតាមវិស័យ
៤. ការគ្រប់គ្រង និងអភិវឌ្ឍន៍ស្ថាប័ន

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីចមានក្នុង តារាង ៨នៃឧបសម្ព័ន្ធ

**ក្រសួងធម្មការ និងសាសនា** មានគោលនយោបាយចំនួន ១ គឺ÷ លើកកម្ពស់សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គម និងសុខដុមនីយកម្មសាសនា។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

៦៥ ៧០៦ លានរៀល

អភិវឌ្ឍសុខដុមនីយកម្មសាសនានៅកម្ពុជា

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៩នៃឧបសម្ព័ន្ធ

**ក្រសួងទេសចរណ៍**មានគោលនយោបាយចំនួន ១ គឺ÷ ជំរុញកំណើនទេសចរណ៍ និងបង្កើនតម្លៃបន្ថែមតាមរយៈវិស័យទេសចរណ៍នៅកម្ពុជា។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

៩៥ ០៦៥ លានរៀល

១. គ្រប់គ្រងឧស្សាហកម្មទេសចរណ៍

២. អភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ

៣. សេវាគាំទ្រដំណើរការទូទៅសម្រាប់ការគ្រប់គ្រងវិស័យទេសចរណ៍

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១០នៃឧបសម្ព័ន្ធ

**ក្រសួងធនធានទឹក និងឧតុនិយម**មានគោលនយោបាយចំនួន ១ គឺ÷ ការគ្រប់គ្រង អភិវឌ្ឍន៍ និងអភិរក្សធនធានទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់ សមធម៌ និងនិរន្តរភាព។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១៥៩ ១៧៧ លានរៀល

១. ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក

២. ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត

៣. ការការពារ និងអភិរក្សធនធានទឹក

៤. ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹក និងឧតុនិយម

៥. ការកែលម្អការគ្រប់គ្រងរដ្ឋបាល និងអភិវឌ្ឍន៍ធនធានមនុស្ស

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១១នៃឧបសម្ព័ន្ធ</u>

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**មានគោលនយោបាយចំនួន ១ គឺ÷ជំរុញកំណើនកសិកម្ម និងបង្កើនការនាំចេញផលិតផលកសិកម្មប្រកបដោយគុណភាព និងសុវត្ថិភាព តាមរយៈការលើកកម្ពស់ផលិតភាពកសិកម្ម បង្កើនតម្លៃបន្ថែម និងពង្រីកការប្រកួតប្រជែងទីផ្សារ ព្រមទាំងរក្សាបានតុល្យភាពនៃការប្រើប្រាស់ដីកសិកម្ម និងធានាការគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

២៦៨ ៩២៨ លានរៀល

១. បង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម

២. ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ

៣. គ្រប់គ្រងធនធានជលផល និងអភិវឌ្ឍវារីវប្បកម្ម

៤. គ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ

៥. ពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១២នៃឧបសម្ព័ន្ធ</u>

**ក្រសួងពាណិជ្ជកម្ម** មានគោលនយោបាយចំនួន ១ គឺ÷ ពង្រឹង និង ជំរុញការអភិវឌ្ឍ វិស័យពាណិជ្ជកម្ម។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៣ គឺ÷

១៨៧ ១៦៧ លានរៀល

១. ការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍន៍វិស័យឯកជន

២. ការផ្តល់សេវាត្រួតពិនិត្យទំនិញ និងការអនុវត្តច្បាប់

៣. ពង្រឹងស្ថាប័ន និងជំរុញសមាហរណកម្ម និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មក្នុងប្រទេសនិងក្រៅប្រទេស

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១៣ នៃឧបសម្ព័ន្ធ</u>

**ក្រសួងរ៉ែ និងថាមពល** មានគោលនយោបាយចំនួន ១ គឺ÷ ជំរុញការអភិវឌ្ឍ និង គ្រប់គ្រងវិស័យរ៉ែ និងថាមពល។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៤ គឺ÷

៥៦ ៣៦៤ លានរៀល

១. អភិវឌ្ឍន៍និងគ្រប់គ្រងវិស័យធនធានរ៉ែ

២. អភិវឌ្ឍន៍និងគ្រប់គ្រងវិស័យប្រេងកាត

៣. អភិវឌ្ឍន៍និងគ្រប់គ្រងវិស័យថាមពល

៤. ការអភិវឌ្ឍស្ថាប័ន និងការគាំទ្រផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១៤នៃឧបសម្ព័ន្ធ</u>

**ក្រសួងសាធារណការនិងដឹកជញ្ជូន**មានគោលនយោបាយចំនួន ១ គឺ÷

អភិវឌ្ឍន៍ ថែទាំ និងគ្រប់គ្រងសំណង់សាធារណការ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន មធ្យោបាយសេវាកម្មដឹកជញ្ជូនគ្រប់ប្រភេទ និងភស្តុភារកម្មប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន២ គឺ÷

៩០២ ៣៨៥ លានរៀល

១. អភិវឌ្ឍន៍ ជួសជុល ថែទាំ និងគ្រប់គ្រងសំណង់សាធារណការ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម

២. គាំទ្រគោលនយោបាយសាធារណការ, ដឹកជញ្ជូន, ការអភិវឌ្ឍន៍ធនធានមនុស្ស និងគ្រប់គ្រងរដ្ឋបាលទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១៥នៃឧបសម្ព័ន្ធ</u>

**ក្រសួងអភិវឌ្ឍន៍ជនបទ** មានគោលនយោបាយចំនួន ២ គឺ÷

ទី ១ ÷ ធានាលើកកម្ពស់កម្រិតជីវភាពរស់នៅ របស់ប្រជាពលរដ្ឋជនបទ ឱ្យមានគម្លាតខិតជិតទីប្រជុំជននៅឆ្នាំ ២០២៥។

ទី ២ ÷ ជម្រុញកំណើនសេដ្ឋកិច្ចជនបទ តាមរយៈការអភិវឌ្ឍន៍ជនបទ ចម្រុះដោយមានការចូលរួមពីសហគមន៍ជាតិ និងអន្តរជាតិ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៣ គឺ÷

១៨៣ ២៩៥ លានរៀល

១. ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ

២. កិច្ចអន្តរាគមន៍គាំទ្រសេវាទំនាក់ទំនងជនបទ

៣. ការអភិវឌ្ឍន៍ស្ថាប័ន និងការគាំទ្រផ្នែកសេវារដ្ឋបាល និងហិរញ្ញវត្ថុ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១៦នៃឧបសម្ព័ន្ធ</u>

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** មានគោលនយោបាយចំនួន ១ គឺ៖ បន្តអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៤ គឺ៖

៧៣ ៩៦៤
លានរៀល

១. ការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យប្រៃសណីយ៍និងទូរគមនាគន៍
២. ការគ្រប់គ្រង និងអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
៣. ការគ្រប់គ្រងរដ្ឋបាល ធនធានមនុស្ស ហិរញ្ញវត្ថុនិងថវិកា និងពង្រឹងការត្រួតពិនិត្យ និងអភិបាលកិច្ច
៤. អប់រំបណ្តុះបណ្តាល ស្រាវជ្រាវ និងនវានុវត្តន៍ក្នុងវិស័យ ប.ទ និង ICT

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១៧នៃឧបសម្ព័ន្ធ

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម** មានគោលនយោបាយចំនួន ១ គឺ៖ ការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្មនិងការផ្គត់ផ្គង់ទឹកស្អាត។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៣ គឺ៖

៥៧ ៣៦៣
លានរៀល

១. ការបង្កើនការកសាងមូលដ្ឋានអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងការផ្គត់ផ្គង់ទឹកស្អាត
២. ការបង្កើនចលករគាំទ្រ និងពង្រឹងសមត្ថភាពនៃការអភិវឌ្ឍឧស្សាហកម្មនិងសិប្បកម្ម
៣. ការបង្កើនសេវាទ្រទ្រង់ដំណើរការកិច្ចការទូទៅ ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ១៨នៃឧបសម្ព័ន្ធ

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** មានគោលនយោបាយចំនួន ១ គឺ÷ លើកកម្ពស់គុណភាពសេវាកម្ម និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិលដើម្បីធានាសុវត្ថិភាព និងសន្តិសុខសម្រាប់សហប្រតិបត្តិការដឹកជញ្ជូនផ្លូវអាកាស។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន២ គឺ÷

៥៥ ៨១២ លានរៀល

១. ការធានាសុវត្ថិភាព សន្តិសុខ និងការគ្រប់គ្រងស្តង់ដាអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសចរស៊ីវិល

២. ការអភិវឌ្ឍន៍ស្ថាប័ន និងសេវាគាំទ្រផ្នែករដ្ឋបាលហិរញ្ញវត្ថុ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ១៩នៃឧបសម្ព័ន្ធ</u>

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មានគោលនយោបាយចំនួន ២ គឺ÷

ទី ១ ÷ ពង្រឹង និងបង្កើនប្រសិទ្ធភាពគ្រប់គ្រងសេដ្ឋកិច្ច និងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។

ទី ២ ÷ ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ទ្រព្យសម្បត្តិរដ្ឋ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

៧៦ ១៥៥ លានរៀល

១. ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសេដ្ឋកិច្ច

២. ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង ការត្រួតពិនិត្យ និងការអភិវឌ្ឍ វិស័យហិរញ្ញវត្ថុ

៣. ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកៀរគរចំណូលថវិកាជាតិ និងទ្រព្យសម្បត្តិរដ្ឋ

៤. ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយសាធារណៈ

៥. ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគាំទ្រទូទៅនិងការធានាគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២០ នៃឧបសម្ព័ន្ធ</u>

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** មានគោលនយោបាយចំនួន ១ គឺ÷
ពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សតាមរយៈការបោះឆ្នោត។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន២ គឺ÷

៧៩ ០៥៩
លានរៀល

១. ពង្រឹងបទបញ្ញា នីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងបទបញ្ញាផ្ទៃក្នុងនៃ គ.ជ.ប
២. ពង្រឹងដំណើរការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២១នៃឧបសម្ព័ន្ធ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** មានគោលនយោបាយចំនួន ១ គឺ÷
កំណែទម្រង់វិស័យដីធ្លី និងការអភិវឌ្ឍន៍វិស័យសំណង់ និងលំនៅឋាន។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

១៦២ ៥៩៦
លានរៀល

១. ពង្រឹងការគ្រប់គ្រងដីធ្លី
២. ពង្រឹងការរៀបចំដែនដី និងនគរូបនីយកម្ម
៣. ពង្រឹងការគ្រប់គ្រងវិស័យសំណង់
៤. ការគាំទ្រដំណើរការរដ្ឋបាល និងអភិវឌ្ឍន៍ស្ថាប័ន
៥. លំនៅឋាន

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២២នៃឧបសម្ព័ន្ធ

**ក្រសួងមុខងារសាធារណៈ** មានគោលនយោបាយចំនួន ១ គឺ÷ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈ និងពង្រឹងការកែលម្អអភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៤ គឺ÷

៩៣ ៩១៩ លានរៀល

១. កំណែទម្រង់រដ្ឋបាលសាធារណៈ
២. ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យសាធារណៈ
៣. ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងមន្ត្រីរាជការ និងការកែលម្អរបៀបរបបគ្រប់គ្រង និងចាត់ចែងការងារ
៤. ការគាំទ្រ និង ការសម្របសម្រួលកិច្ចការទូទៅរបស់ក្រសួង-មន្ទីរក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២៣នៃឧបសម្ព័ន្ធ</u>

**ក្រសួងផែនការ** មានគោលនយោបាយចំនួន ១ គឺ÷ អភិវឌ្ឍ និងជំរុញការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យ ផែនការស្ថិតិ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន៥ គឺ÷

៩១ ១៣៨ លានរៀល

១. អភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍក្នុងវិស័យផែនការ
២. ពង្រឹងប្រព័ន្ធស្ថិតិជាតិ
៣. សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជន២០១៦-២០៣០
៤. សម្របសម្រួល និងជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
៥. ការគាំទ្រកិច្ចការរដ្ឋបាលទូទៅ និងការអភិវឌ្ឍស្ថាប័ន

គម្រោងចំណាយថវិកាឆ្នាំ ២០១៨ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ២៤នៃឧបសម្ព័ន្ធ</u>

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** មានគោលនយោបាយចំនួន ១ គឺ៖ ពង្រឹង និងលើកកម្ពស់គោលនយោបាយការបរទេស ក្នុងការបន្តធ្វើសមាហរណកម្មកម្ពុជាកាន់តែស៊ីជម្រៅទៅក្នុងតំបន់ និងពិភពលោក។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ៖

លេខរៀង ១៥៥ ៥២

ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងពង្រីកទំនាក់ទំនងការងារការទូត នៅលើពិភពលោក

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៥នៃឧបសម្ព័ន្ធ

**អង្គភាពប្រឆាំងអំពើពុករលួយ** មានគោលនយោបាយចំនួន ១ គឺ៖ ពង្រឹង អភិបាលកិច្ចល្អតាមរយៈការកាត់បន្ថយអំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់ សំដៅធ្វើឱ្យសម្រេចបាននូវការអភិវឌ្ឍសង្គម សេដ្ឋកិច្ចមួយ ប្រកបដោយ ចីរភាព ស្ថិរភាព និងសមធម៌។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន២ គឺ៖

លេខរៀង ៤៥ ៥៦

១. ពង្រឹងវិធានការអប់រំ បង្ការទប់ស្កាត់ និងអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ

២. ការពង្រឹងសេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៦នៃឧបសម្ព័ន្ធ

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**មានគោលនយោបាយចំនួន ១ គឺ÷ លើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន និងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

**១៥ ៩៣០ លានរៀល**

ពង្រឹង និងពង្រីកវិស័យឯកជន និងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៧នៃឧបសម្ព័ន្ធ

**អាជ្ញាធរសវនកម្មជាតិ**មានគោលនយោបាយចំនួន ១ គឺ÷ រួមចំណែកលើកស្ទួយអភិបាលកិច្ចល្អ និងការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

**១៨ ២០៥ លានរៀល**

ពង្រឹងការគ្រប់គ្រង និងសម្របសម្រួលការងារសវនកម្មប្រកបដោយប្រសិទ្ធភាព

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៨នៃឧបសម្ព័ន្ធ

**ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** មានគោលនយោបាយចំនួន ១ គឺ÷ ការលើកកម្ពស់អភិបាលកិច្ចល្អតាមរយៈ ការអប់រំ បង្ការ ទប់ស្កាត់បាតុភាពអសកម្ម បង្កើនគណនេយ្យភាព ប្រសិទ្ធភាពការងារ និង ពង្រឹងនីតិរដ្ឋ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

**៨១ ៥៥៦ លានរៀល**

បង្កើននិងពង្រឹងប្រសិទ្ធភាពវិស័យទំនាក់ទំនងជាមួយរដ្ឋសភា - ព្រឹទ្ធសភា និងអធិការកិច្ច

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ២៩នៃឧបសម្ព័ន្ធ

**ក្រុមប្រឹក្សាធម្មនុញ្ញ**មានគោលនយោបាយចំនួន ១ គឺ÷ គោរពនីតិរដ្ឋ ការពារឯករាជ្យភាព អនុវត្តអព្យាក្រឹតភាពក្នុងការបំពេញមុខងារ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

**១១ ៥២៣ លានរៀល** ធានាការគោរពនីតិរដ្ឋ ការពារឯករាជ្យភាព អនុវត្តអព្យាក្រឹតភាព

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣០នៃឧបសម្ព័ន្ធ

**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**មានគោលនយោបាយចំនួន ១ គឺ÷ ពង្រឹង និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

**៥៧ ២៣៣ លានរៀល** ពង្រឹងការអនុវត្តមុខងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣១នៃឧបសម្ព័ន្ធ

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**មានគោលនយោបាយចំនួន ១ គឺ÷ លើកកម្ពស់នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស តាមរយៈការអនុវត្តតួនាទីនៃមុខងារនីតិបញ្ញត្តិ និងការរួមចំណែកជម្រុញសមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

**១៥៣ ៧៥៣ លានរៀល**

១. លើកកម្ពស់ការអនុវត្តការងារ និងតួនាទីនីតិបញ្ញត្តិរបស់ស្ថាប័នរដ្ឋសភា
២. លើកកម្ពស់ការអនុវត្តការងារការទូតរបស់រដ្ឋសភាក្នុងតំបន់ និងពិភពលោក
៣. ការពង្រឹងធនធានមនុស្ស និងបង្កើនគុណភាពសេវាជូនរដ្ឋសភា

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣២នៃឧបសម្ព័ន្ធ

**ក្រសួងព្រះបរមរាជវាំង**មានគោលនយោបាយចំនួន ១ គឺ÷ បម្រើសេវាឱ្យកាន់តែល្អប្រសើរ ថ្វាយព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងការបំពេញព្រះរាជបេសកកម្មបម្រើប្រទេសជាតិ ឱ្យមានការអភិវឌ្ឍន៍ និងមានកិត្តិយសលើឆាកអន្តរជាតិ តាមព្រះរាជកិច្ចរបស់ព្រះអង្គដែលរដ្ឋធម្មនុញ្ញបានកំណត់។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១ គឺ÷

**៩៨ ៤១៤ លានរៀល** — ព្រះរាជកិច្ច ព្រះមហាក្សត្រ និង សម្តេចព្រះវររាជមាតាជាតិខ្មែរ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣៣នៃឧបសម្ព័ន្ធ

**ទីស្តីការគណៈរដ្ឋមន្ត្រី**មានគោលនយោបាយចំនួន ១ គឺ÷ បន្តដឹកនាំសម្របសម្រួលការរៀបចំ និងអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ដើម្បីការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ១គឺ÷

**៤១៥ ៤០៩ លានរៀល** — ពង្រឹងប្រសិទ្ធិភាពការកសាង និងអនុវត្តគោលនយោបាយនិងកំណែទម្រង់រដ្ឋ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣៤នៃឧបសម្ព័ន្ធ

**ក្រសួងការពារជាតិ**មានគោលនយោបាយចំនួន ១ គឺ÷ ការពារ អធិបតេយ្យ បូរណភាពទឹកដី រក្សាសន្តិសុខនិងសុវត្ថិភាពសង្គម។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៤ គឺ÷

**២ ៤១៦ ៤៣៧ លានរៀល**

១. ដឹកនាំបញ្ជា ហ្វឹកហ្វឺន ធ្វើប្រតិបត្តិការ ការពារសុខសន្តិភាព និងរក្សាសណ្តាប់ធ្នាប់សង្គម
២. សហប្រតិបត្តិការយោធាក្នុងតំបន់ និងអន្តរជាតិ
៣. ថែទាំគ្រឿងបំពាក់បច្ចេកទេស វិស្វកម្ម និងបញ្ជូនសារ
៤. សេវាគាំទ្ររដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង តារាង ៣៥នៃឧបសម្ព័ន្ធ

**ក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ)** មានគោលនយោបាយចំនួន ១ គឺ÷ ពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

**១ ៤៩០ ៧០៩ លានរៀល**

១. កិច្ចការពារសន្តិសុខជាតិ និងការរក្សាសណ្តាប់ធ្នាប់សាធារណៈ
២. កិច្ចការពារសុវត្ថិភាពសង្គម
៣. សេវាគាំទ្រកិច្ចប្រតិបត្តិការទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣៦នៃឧបសម្ព័ន្ធ</u>

**ក្រសួងមហាផ្ទៃ (ផ្នែករដ្ឋបាលទូទៅ)** មានគោលនយោបាយចំនួន ១ គឺ÷ ដឹកនាំ គ្រប់គ្រងរដ្ឋបាលដែនដី ដើម្បីលើកកម្ពស់សេវាសាធារណៈ និងការអភិវឌ្ឍ។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

**២០៦ ០៣៩ លានរៀល**

១. ការគ្រប់គ្រងរដ្ឋបាលដែនដី
២. ការគ្រប់គ្រងពន្ធនាគារ
៣. សេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣៧នៃឧបសម្ព័ន្ធ</u>

**ក្រសួងយុត្តិធម៌** មានគោលនយោបាយចំនួន ១ គឺ÷ បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌។

ដើម្បីសម្រេចគោលបំណងគោលនយោបាយខាងលើ ក្រសួងបានរៀបចំកម្មវិធីចំនួន ៣ គឺ÷

**១៥០ ៣៧១ លានរៀល**

១. កិច្ចការច្បាប់
២. កិច្ចការតុលាការ
៣. សេវាគាំទ្រទូទៅ

គម្រោងចំណាយថវិកាឆ្នាំ ២០១៩ ត្រូវបានបែងចែកទៅតាមកម្មវិធី និងអនុកម្មវិធីដូចមានក្នុង <u>តារាង ៣៨នៃឧបសម្ព័ន្ធ</u>

## ៣.៤. ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០១៩

